# កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ចិន

## ភ្នំពេញ, ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២២

## សុន្ទរកថាបើក

## សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

**ឯកឧត្តម វៃ ហ្វេងហ៉េ (Wei Fenghe) សមាជិកក្រុមប្រឹក្សារដ្ឋ រដ្ឋមន្ត្រីកាពារជាតិនៃសាធារណរដ្ឋប្រជាមានិតចិន!**

**ឯកឧត្តមរដ្ឋមន្ត្រីការពារជាតិអាស៊ានទាំងអស់!**

**លោក លោកស្រី!**

ជាបឋម តាំងនាមឱ្យរាជរដ្ឋាភិបាល និងក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**ឯកឧត្តម វៃ ហ្វេងហ៉េ** សមាជិកក្រុមប្រឹក្សារដ្ឋ រដ្ឋមន្ត្រីកាពារជាតិនៃ ាធារណរដ្ឋប្រជាមានិតចិន រដ្ឋមន្ត្រីការពារជាតិអាស៊ាន ដែលបានចំណាយពេលដ៏មានតម្លៃចូលរួមនៅក្នុងកិច្ចប្រជុំក្រៅផ្លូវការ រដ្ឋមន្ត្រីការពារជាតិ អាស៊ាន-ចិន នាពេលនេះ។ ពិតណាស់ វាជារឿងគួរឱ្យសោកស្តាយដែល**ឯកឧត្តម ហ្វេងហ៉េ** មិនបានចូលរួមកិច្ចប្រជុំនេះដោយផ្ទាល់នៅកម្ពុជា ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការចូលរួមរបស់ឯកឧត្តមតាមប្រព័ន្ធវីដីអូ នៅពេលនេះ បានបង្ហាញយ៉ាងច្បាស់នូវការប្តេជ្ញាចិត្តរបស់ឯកឧត្តម ក្នុងការបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការការពារជាតិជាមួយនឹងអាស៊ាន ឱ្យកាន់តែល្អប្រសើរ។

នៅក្នុងរយៈពេល៣០ឆ្នាំចុងក្រោយនេះ កិច្ចសហប្រតិបត្តិការអាសាន-ចិន មានការរីកចម្រើនខ្លាំងគួរឱ្យកត់សម្គាល់លើគ្រប់វិស័យ ដែលបានផ្តល់នូវគុណប្រយោជន៍ទៅវិញទៅមក និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកម្ពស់សន្តិភាព ស្ថិរភាព សន្តិសុខ ការអភិវឌ្ឍ និងវិបុលភាពក្នុងតំបន់ ។ ជាក់ស្តែងចាប់តាំងពីឆ្នាំ២០០៩ សាធារណរដ្ឋប្រជាមានិតចិន គឺជាដៃគូពាណិជ្ជកម្មដ៏ធំរបស់អាស៊ាន ហើយនៅក្នុងឆ្នាំ២០២០ អាស៊ានក៏បានក្លាយជាដៃគូពាណិជ្ជកម្មដ៏ធំរបស់សាធារណរដ្ឋប្រជាមានិតចិន និងបានបន្តរហូតមកដល់ឆ្នាំ២០២២ ដែលតម្លៃស្មើនឹង ២៧៤.៥ ពាន់លានដុល្លារអាមេរិក ឬ ១៤.៦ ភាគរយនៃពាណិជ្ជកម្មបរទេសសរុបរបស់ចិន។

ទន្ទឹមនឹងនេះ នៅក្នុងកិច្ចប្រជុំកំពូលពិសេសអាស៊ាន-ចិន ដើម្បីរំលឹកខួបអនុស្សាវរីយ៍លើកទី៣០ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-ចិន កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ថ្នាក់ដឹកនាំអាស៊ាន-ចិន បានឯកភាពបង្កើតភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដែលគឺជាការបើកទំព័រថ្មីនៃប្រវត្តិសាស្ត្រទំនាក់ទំនងអាស៊ាន-ចិន ជាពិសេសសម្រាប់ទំនាក់ទំនងការពារជាតិអាស៊ាន-ចិន។ ថ្នាក់ដឹកនាំអាស៊ាន-ចិន បានឯកភាពគ្នាបន្តលើកកម្ពស់ កិច្ចសហប្រតិបត្តិការសន្តិសុខ-នយោបាយ តាមរយៈការរក្សាឱ្យមានជំនួបថ្នាក់ដឹកនាំជាន់ខ្ពស់ និងគ្រប់ជាន់ថ្នាក់ ដើម្បីចែករំលែកបទពិសោធន៍និងធ្វើឱ្យមានការជឿជាក់គ្នាទៅវិញទៅមកកាន់តែស៊ីជម្រៅ និងលើកកម្ពស់កិច្ចសន្ទនានិងការសម្របសម្រួល តាមរយៈក្របខណ្ឌដែលដឹកនាំដោយអាស៊ាន។ ទន្ទឹមនឹងនេះ ចិន និងអាស៊ាន ប្តេជ្ញាពង្រឹងជំនួបការពារជាតិនិងកិច្ចសហប្រតិបត្តិការសន្តិសុខ តាមរយៈក្របខណ្ឌនិងយន្តការដែលមានស្រាប់ដូចជា កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក និងវេទិកាតំបន់អាស៊ាន និងការគាំទ្រដល់ការខិតខំរបស់អាស៊ាន ក្នុងការរក្សាតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ និងដើម្បីឈានទៅដល់ការកសាងសហគមន៍ជោគវាសនារួម។

ជាមួយគ្នានេះដែរ សាធារណរដ្ឋប្រជាមានិតចិន កំពុងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តសេចក្តីថ្លែងការណ៍ ស្តីពីការប្រតិបត្តិរបស់បណ្តាភាគីនៅសមុទ្រចិនខាងត្បូង (DOC) និងបន្តជម្រុញក្នុងការឆ្ពោះទៅរកការសម្រេចបាននូវក្រមប្រតិបត្តិ (COC) ប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បីធានាដល់ស្ថិរភាព និងសន្តិភាពក្នុងតំបន់។

ឆ្លៀតក្នុងឱកាសនេះ តាងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសំដែងនូវការដឹងគុណយ៉ាងក្រៃលែង ចំពោះការជួយឧបត្ថម្ភគាំទ្ររបស់សាធារណរដ្ឋប្រជាមានិតចិន តាំងពីដំបូង នៅក្នុងការតស៊ូប្រយុទ្ធជាមួយជំងឺកូវីដ១៩ ដោយបង្កលក្ខណៈឲ្យកម្ពុជាមានមូលដ្ឋានរឹងមាំ អាចយកជ័យជំនះលើជំងឺដ៏កាចសាហាវនេះ បានស្ទើរទាំងស្រុង រហូតមកទល់ពេលនេះ។ ជាមួយនេះដែរ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះចំណងមិត្តភាពពិតប្រាកដ និងការជួយយកអាសារគ្នាទៅវិញទៅមក រវាងចិន និងកម្ពុជា ជំរុញការអភិវឌ្ឍន៍ប្រទេសជាតិ លើគ្រប់វិស័យ ជាពិសេសនៅក្នុងការធ្វើទំនើបកម្មកងយោធពលខេមរភូមិន្ទ ស្ថិតក្រោមស្មារតីគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។

ជាកិច្ចបន្ទាប់ ខ្ញុំសូមគោរពអញ្ជើញ**ឯកឧត្តម វ៉ៃ ហ្វេងហ័រ** សមាជិកក្រុមប្រឹក្សារដ្ឋ រដ្ឋមន្ត្រីការពារជាតិនៃសាធារណរដ្ឋប្រជាមានិតចិន ធ្វើសុន្ទរកថា។

ឯកឧត្តម លោក លោកស្រី

ខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តម លោក លោកស្រី ដែលបានផ្តល់ការគាំទ្រ និងចូលរួមចំណែកយ៉ាងសំខាន់ដល់ជោគជ័យនៃក្នុងកិច្ចប្រជុំរបស់យើង នាពេលនេះ។ ឥឡូវ យើងឈានដល់ការបញ្ចប់នៃកិច្ចប្រជុំក្រៅផ្លូវការ រដ្ឋមន្ត្រីការពារជាតិអាស៊ាន-ចិន របស់យើង។ មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងសុន្ទរកថាបិទដូចខាងក្រោមៈ

**ឯកឧត្តម វ៉ៃ ហ្វេងហ៉េ សមាជិកក្រុមប្រឹក្សារដ្ឋ រដ្ឋមន្ត្រីកាពារជាតិនៃសាធារណរដ្ឋប្រជាមានិតចិន!**
**ឯកឧត្តមរដ្ឋមន្ត្រីការពារជាតិអាស៊ាន!**
**លោក លោកស្រី!**

ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀតចំពោះ**ឯកឧត្តម វ៉ៃ ហ្វេងហ៉េ** សមាជិកក្រុមប្រឹក្សារដ្ឋ រដ្ឋមន្ត្រីកាពារជាតិនៃសាធារណរដ្ឋប្រជាមានិតចិន រដ្ឋមន្ត្រីការពារជាតិអាស៊ាន ដែលមានចូលរួមនៅក្នុងកិច្ចប្រជុំក្រៅផ្លូវការ រដ្ឋមន្ត្រីការពារជាតិអាស៊ាន-ចិន និងបានចែករំលែកនូវទស្សនៈ និងផ្តល់អនុសាសន៍សំខាន់ៗជុំវិញប្រធានបទនៃបញ្ហាសន្តិ

សុខក្នុងតំបន់ និងពិភពលោក ក៏ដូចជាការលើកកម្ពស់កិច្ចសហប្រតិបត្តិការការពារជាតិ អាស៊ាន-ចិន នៅក្រោមក្របខណ្ឌដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងដើម្បីឈានដល់ការកសាងសហគមន៍ជោគវាសនារួម ដែលមានសារៈសំខាន់នៅក្នុងការរក្សានិងលើកកម្ពស់សន្តិភាព ស្ថិរភាព សន្តិសុខ ការអភិវឌ្ឍ និងវិបុលភាពតំបន់ និងពិភពលោក។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចប្រជុំក្រៅផ្លូវការ រដ្ឋមន្ត្រីការពារជាតិអាស៊ាន-ចិន ដែលទទួលបាននូវលទ្ធផលប្រកបដោយផ្លែផ្កា ហើយមុននឹងបញ្ចប់ ខ្ញុំសូមធ្វើការសង្ខេបនូវចំណុចសំខាន់ៗដែលបានលើកឡើងនៅថ្ងៃនេះ។

នៅក្នុងកិច្ចប្រជុំក្រៅផ្លូវការ រដ្ឋមន្ត្រីការពារជាតិអាស៊ាន-ចិន ភាគីអាស៊ាន-ចិន បានធ្វើការពិភាក្សា និងផ្លាស់ប្តូរនូវទស្សនៈទៅលើប្រធានបទនៃបញ្ហាប្រឈមផ្នែកសន្តិសុខនៅក្នុងតំបន់ និងពិភពលោក រួមមានទាំងបញ្ហាសន្តិសុខប្រពៃណី និងមិនប្រពៃណី ក៏ដូចជំងឺកូវីដ-១៩ ដែលបាននិងកំពុងបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យសេដ្ឋកិច្ចសន្តិសុខថាមពល និងស្បៀង និងបង្កឱ្យមានភាពមិនច្បាស់លាស់ និងព្រួយបារម្ភចំពោះអនាគតសន្តិសុខពិភពលោក។ ជាមួយគ្នានេះផងដែរ យើងហាក់មានសុទិដ្ឋិនិយមចំពោះកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន នៅក្នុងវិស័យការពារជាតិ ជាពិសេសនៅក្រោមក្របខណ្ឌដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដែលនឹងបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការការពារជាតិរវាងអាស៊ាន-ចិន ឱ្យកាន់តែរីកចម្រើនបន្ថែមទៀត ពង្រឹងជំនឿទុកចិត្តលើគ្នាទៅវិញទៅមក ចូលរួមដោះស្រាយបញ្ហាដែលជាកង្វល់រួម និងចូលរួមលើកកម្ពស់ការកសាងសមត្ថភាពក្នុងវិស័យការពារជាតិ។ ម្យ៉ាងទៀត យើងសូមកោតសរសើរចំពោះសាធារណរដ្ឋប្រជាមានិតចិនដែលបានបន្តគោរពគោលការណ៍អាស៊ាន ដែលស្របគ្នាជាមួយនឹងគោលបំណងនៃការកសាងសហគមន៍ជោគវាសនារួម ក្នុងការបន្តលើកកម្ពស់ពហុភាគីនិយម ការគោរពគ្នាទៅវិញទៅមក សមភាព បដិសេធចំពោះការកៀបសង្កត់ និងការប្រើប្រាស់កម្លាំង ប្រកាន់យកដំណោះស្រាយដោយសន្តិវិធី លើកកម្ពស់ការពិគ្រោះយោបល់លើបញ្ហាធ្ងន់ធ្ងរនិងប្រកាន់ភ្ជាប់នូវនីតិរដ្ឋ និងលើកតម្កើងធម្មនុញ្ញអង្គការសហប្រជាជាតិនិងច្បាប់អន្តរជាតិ ។ល។និង។ល។

កម្ពុជាសង្ឃឹមថា អាស៊ាន-ចិន នឹងបន្តរក្សាសន្ទុះនៃកិច្ចសហប្រតិបត្តិការនេះ ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា និងការលើកកម្ពស់សេដ្ឋកិច្ចតំបន់ ជាពិសេសជាមួយនឹងពិភពលោកដែលកំពុងជួបនឹងបញ្ហាស្មុគស្មាញជាច្រើន។ កិច្ចសហប្រតិបត្តិការអាស៊ាន-ចិន គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាព សន្តិសុខ ការអភិវឌ្ឍ និងវិបុលភាពតំបន់ ជាពិសេសការស្តារឡើងវិញក្រោយជំងឺកូវីដ-១៩។ សារជាថ្មីម្តងទៀត កម្ពុជាក៏សូមជំរុញឱ្យភាគីអាស៊ាន-ចិន បន្តការអនុវត្តសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិរបស់បណ្តាភាគីនៅសមុទ្រចិនខាងត្បូង (DOC) និងការសម្រេចឱ្យបាននូវក្រមប្រតិបត្តិ (COC) ដែលប្រកបដោយប្រសិទ្ធភាព និងចីរភាព ក្នុងពេលឆាប់ៗ ដើម្បីធានាដល់ស្ថិរភាព និងសន្តិភាពក្នុងតំបន់។ ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមប្រកបដោយសុខភាពល្អ សុភមង្គល និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

សូមអរគុណ!